រក្សាសិទ្ធិ © ពត៌មាន :
© ២០០១ Project WorldReach © ២០០១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

007KH01A-01

របៀបបង្កើតសាវ័ក



កូនស្បៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៧

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

យោបល់ស្នើជូនសំរាប់ការប្រើមេរៀននេះ

ជូនអត្ថបទសិក្សាម្តងមួយទៅអ្នកជឿថ្មី ។ អោយពួកគេសិក្សានៅផ្ទះសិន រួចអោយពួកគេមកជួបជាមួយអ្នកជាក្រុម បើអាចធ្វើបាន ។ មេរៀននេះ មានអត្ថបទសិក្សាចំនួនប្រាំពីរ ហើយអត្ថបទនិមួយៗនឹងជួយពួកគេអោយអាចអនុវត្តតាមសេចក្តីបង្គាប់ជាគ្រឹះមួយរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត ដែលមានដាក់ជូនជាបន្តបន្ទាប់ទៅនេះ ។ (ដើម្បីអាចជួយដល់ការបង្កើតសាវ័ក សេចក្តីបង្គាប់ទាំងនេះត្រូវបានសង្ខេបជាសេចក្តីបង្គាប់សំខាន់ៗចំនួន ៧) ។ សេចក្តីបង្គាប់ផ្សេងៗទៀតរបស់ព្រះអម្ចាស់ ក៏បញ្ជាក់ពីសេចក្តីសំខាន់ប្រហែលគ្នានឹងសេចក្តីបង្គាប់ទាំងប្រាំពីរនោះដែរ ។

- **កែប្រែចិត្តគំនិត** និង**ជឿ** ដើម្បីអោយព្រះជាម្ចាស់លើកលែងទោសអំពើបាប និងដើម្បីអោយបានទទួលព្រះវិញ្ញាណដ៏-វិសុទ្ធ (ដែលធ្វើអោយយើងដឹងថាព្រះយេស៊ូជាអ្នកណា ដឹងពីកិច្ចការដែលព្រះអង្គធ្វើដើម្បីយើង និងដឹងថាយើងត្រូវដើរតាមព្រះអង្គដោយជំនឿ និងដោយស្តាប់បង្គាប់) ។

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

- **ទទួលពិធីជ្រមុជទឹក** (ហើយត្រូវរស់នៅដោយមានជីវិតថ្មី ស្របតាមអត្ថន័យរបស់ពិធីជ្រមុជទឹក ។ ត្រូវដឹងថាព្រះ-វិញ្ញាណដ៏វិសុទ្ធជានរណា ហើយព្រះអង្គធ្វើកិច្ចការអ្វីខ្លះសំរាប់យើង) ។
- **ស្រឡាញ់**ព្រះជាម្ចាស់ អ្នកជឿឯទៀត ក្រុមគ្រួសារ និងអ្នកជិតខាងរបស់យើង ព្រមទាំងសត្រូវរបស់យើងទៀតផង ។ (យើងត្រូវធ្វើកិច្ចការបំរើខ្លះ ដែលបង្ហាញពីសេចក្តីស្រឡាញ់របស់យើងដោយការប្រព្រឹត្ត) ។
- ចូលរួម**ធ្វើពិធីកាច់នំបុ័ង**ដោយទៀងទាត់ (និងត្រូវរួមចិត្តគំនិតជាមួយព្រះគ្រីស្ត និងក្រុមជំនុំរបស់ព្រះអង្គជាប់ជានិច្ចតាមអត្ថន័យរបស់ពិធីកាច់នំបុ័ង) ។
- **អធិស្ឋាន** និងរិះគិតពិចារណាពី**ព្រះបន្ទូលព្រះជាម្ចាស់**រាល់ថ្ងៃដោយមានជំនឿរស់ និងសកម្ម(ហើយទទួលផលប្រយោជន៍ពីឯកសិទ្ធិដ៏ធំ ដែលជាការចូលទៅជិតព្រះជាម្ចាស់ដ៏វិសុទ្ធបំផុត ដោយសារព្រះនាមរបស់ព្រះយេស៊ូ) ។

© Project WorldReach © SEAN

- **ចែកចាយ** ឬ **ថ្វាយដង្វាយដប់ភាគរយ** (ដោយថ្វាយរបស់ទ្រព្យ ពេលវេលា សមត្ថភាពរបស់យើង ក្នុងឋានៈជាអ្នកចាត់ចែងលើអ្វីៗគ្រប់យ៉ាងដែលព្រះជាម្ចាស់ប្រទានដល់យើង ដោយស្មោះត្រង់ និងខ្សាហ៍ព្យាយាម) ។
- **បង្កើតសាវ័ក** (**ផ្សាយដំណឹងល្អ**ពីព្រះគ្រីស្ត និង**បង្រៀន**អ្នកដទៃអោយស្តាប់បង្គាប់ព្រះអម្ចាស់ តាមរយៈពាក្យសំដី និងគំរូរបស់យើង) ។

អត្ថបទសិក្សានិមួយៗមានរូបភាព ដែលសំរាប់ធ្វើអោយអ្នកសិក្សាចាប់អារម្មណ៍ពីមេរៀន ។ សូមទុកអោយពួកអ្នកសិក្សាបញ្ចេញយោបល់អំពីន័យរបស់រូបភាពសិន មុននឹងចាប់ផ្តើមសិក្សាមេរៀនណាមួយ ។

កំណត់ចំណាំ

© Project WorldReach © SEAN

សន្លឹកពត៌មានសំរាប់គ្រូបង្ហាត់

គ្រូបង្ហាត់ _____

ក្រុមជំនុំ ឬ ក្រុម _____

សូមសរសេរឈ្មោះអ្នកសិក្សារបស់អ្នក នៅក្នុងបញ្ជីខាងក្រោមនេះ ។ នៅពេលដែលអ្នកអោយអត្ថបទសិក្សាណាមួយទៅអ្នកសិក្សាណាម្នាក់ សូមគូររង្វង់ជុំវិញលេខរបស់អត្ថបទសិក្សានោះ ។ សូមគូរសញ្ញា «×» នៅក្នុងរង្វង់នោះ នៅពេលដែលអ្នកសិក្សាបានធ្វើលំហាត់រួចហើយ ។

អ្នកសិក្សា	អត្ថបទសិក្សា
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧
_____	១ ២ ៣ ៤ ៥ ៦ ៧

អត្ថន័យរបស់រូបភាពទាំងឡាយ

- ព្រះអម្ចាស់យេស៊ូគ្រីស្តបង្ហាញព្រះហស្តរបស់ព្រះអង្គ អោយពួកសាវ័ករបស់ព្រះអង្គមើលនៅថ្ងៃដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ (លូកា ២៤:៣៦-៤៤) ។
- អណ្តាតភ្លើងនៅលើក្បាលពួកសាវ័ក នៅបុណ្យថែទីហាសិប (កិច្ចការ ២) ។
- លោកសង្ឃដែលធ្វើដំណើរតាមផ្លូវទៅក្រុងយេរីខូ ដើរវាងពីបុរសដែលត្រូវរបួស (ដកស្រង់ពីប្រស្នាអំពីអ្នកស្រុកសាម៉ារីដែលមានចិត្តសប្បុរស នៅក្នុងបទគម្ពីរលូកា ១០:២៥-៣៧) ។
- យើងជាមែក ដែលជាប់នឹងដើមទំពាំងបាយជូរ និងដែលបង្កើតផលផ្លែ (យ៉ូហាន ១៥:១-១៧) ។
- នៅពេលដែលអ្នកទារពន្ធម្នាក់អធិស្ឋាននៅក្នុងព្រះវិហារ ទូលសូមអោយព្រះជាម្ចាស់លើកលែងទោសអោយរួចពីបាប នោះ មានអ្នកខាងគណៈផារីស៊ីដែលកាន់ក្រឹត្យវិន័យម្នាក់អធិស្ឋានអួតខ្លួនឯង (លូកា ១៨:៩-១៤) ។

© Project WorldReach © SEAN

- នៅពេលដែលយុវជនអ្នកមានម្នាក់ មិនព្រមលះបង់ទ្រព្យសម្បត្តិខ្លួនដើម្បីដើរតាមព្រះយេស៊ូ ព្រះអង្គមានព្រះបន្ទូលថា « *សត្វអូដ្ឋមួយចូលតាមប្រហោងម្ជុលបាន ស្រួលជាងអ្នកមានម្នាក់ចូលទៅក្នុងព្រះរាជ្យរបស់ស្ថានបរមសុខ*» (លូកា ១៨:១៨-២៥) ។

- បន្ទាប់ពីព្រះយេស៊ូបានធ្វើការអស្ចារ្យ ដើម្បីអោយលោកពេត្រុសចាប់ត្រីបានច្រើនមក ព្រះអម្ចាស់ត្រាស់ហៅគាត់អោយធ្វើជាអ្នកនេសាទមនុស្សវិញ (យ៉ូហាន ២១) ។

នៅចុងបញ្ចប់អត្ថបទសិក្សានិមួយៗ មានពាក្យថា :

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

សូមចុះហត្ថលេខា និងដាក់ថ្ងៃខែ នៅពេលដែលអ្នកបានពិនិត្យឃើញថាអ្នកសិក្សាបាន :

- ឆ្លើយសំណួរត្រឹមត្រូវ ។
- ទន្ទេញខគម្ពីរចាំស្ទាត់ ។
- ធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ :
  - ធ្វើតាមសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។
  - និយាយរឿងក្នុងព្រះគម្ពីរ ប្រាប់ដល់ក្រុមគ្រួសាររបស់ខ្លួន ដោយប្រើរូបភាពបំភ្លឺ ។

(សូមចុះហត្ថលេខា តែនៅពេលដែលអ្នកឃើញលទ្ធផលទាំងអស់នេះហើយ) ។

© Project WorldReach © SEAN